ធនាគារជាតិនៃកម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍



# សារៈសំខាន់នៃប្រាក់រៀលសម្រាប់កម្ពុជា



*National Bank of Cambodia Headquarters in Phnom Penh, Cambodia.*



# សេចក្តីផ្តើម

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ជាតិ គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ។ គោលនយោបាយរូបិយវត្ថុអាចមានប្រសិទ្ធភាពខ្ពស់ទៅបាន នៅពេលដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេស ។ ដោយសារតែកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាជួបប្រទះការលំបាកក្នុងការអនុវត្តដោយប្រសិទ្ធភាពលើបេសកកម្មរបស់ខ្លួន ដោយឧបករណ៍គោលនយោបាយរូបិយវត្ថុដែលអាចប្រើប្រាស់ក្នុងការរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច មានតែមួយចំនួនតូចប៉ុណ្ណោះ ។

មកទល់បច្ចុប្បន្ននេះ ដុល្លារូបនីយកម្មបានរួមចំណែកជាវិជ្ជមានដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចកម្ពុជាដែលមានកំណើនជាមធ្យមប្រមាណ ៨,៥% ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ ។ ល្បឿនកំណើនដ៏គួរឲ្យកត់សម្គាល់នេះត្រូវបានជំរុញដោយការវិនិយោគផ្ទាល់បរទេស ការនាំចេញ និងសមាហរណកម្មយ៉ាងឆាប់រហ័សទៅក្នុងតំបន់និងពិភពលោក ។ ទោះជាយ៉ាងនេះក្តី ខណៈដែលកម្ពុជាកំពុងក្លាយទៅជាប្រទេសមានចំណូលមធ្យម កម្រិតដុល្លារូបនីយកម្មខ្ពស់បានធ្វើឲ្យកម្ពុជាងាយរងឥទ្ធិពលពីខាងក្រៅ និងប្រឈមនឹងហានិភ័យចម្បងៗ ដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ។

រូបិយវត្ថុជាតិតំណាងឲ្យអធិបតេយ្យភាពផ្នែករូបិយវត្ថុ និងភាពរឹងមាំរបស់ជាតិ ។ កម្ពុជាចាំបាច់ត្រូវបង្កើនភាពឯករាជ្យពីការប្រើប្រាស់រូបិយប័ណ្ណដើម្បីធ្វើឲ្យលទ្ធភាពក្នុងការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ដោយយល់ឃើញពីសារៈសំខាន់នៃតួនាទីរបស់រូបិយវត្ថុជាតិក្នុងការជំរុញកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្រ្តជំរុញការប្រើប្រាស់ប្រាក់រៀល ដូចដែលបានចែងនៅក្នុងយុទ្ធសាស្រ្តចតុកោណ និងយុទ្ធសាស្រ្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ ឧទាហរណ៍ការបង់ពន្ធ និងការបង់ថ្លៃទឹក និងថ្លៃអគ្គិសនី ត្រូវធ្វើឡើងជារៀល រួមនឹងការរក្សាតម្លៃប្រាក់រៀលតាមរយៈការធ្វើឲ្យអត្រាប្តូរប្រាក់មានស្ថិរភាពជាដើម ។ កន្លងមកនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាមិនបានប្រើប្រាស់វិធានការរដ្ឋបាល ដើម្បីបង្ខំឲ្យសាធារណជនប្រើប្រាស់ប្រាក់រៀលនោះទេ ដោយហេតុថាវិធានការនេះអាចជំរុញឲ្យមានទីផ្សារងងឹតប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនិងលំហូរមូលធនចេញពីប្រទេស ។ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជានឹងបន្តប្រើប្រាស់វិធីសាស្រ្តលើកទឹកចិត្តក្នុងការប្រើប្រាស់ប្រាក់រៀលជំនួសឲ្យវិធានការរដ្ឋបាល ។

វត្តមានគោលនយោបាយលើកកម្ពស់ប្រាក់រៀលមិនទាន់គ្រប់គ្រាន់ទេ ។ កត្តាសំខាន់ដែលនឹងជួយជំរុញឲ្យមានការផ្លាស់ប្តូរទៅរកការប្រើប្រាស់រូបិយវត្ថុជាតិដើម្បីទទួលបានឯករាជ្យភាពផ្នែករូបិយវត្ថុអាស្រ័យជាចាំបាច់លើការចូលរួមចំណែកពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់គ្នា ។ ការរួមចំណែកទាំងនោះអាចត្រូវបានធ្វើឡើងតាមរយៈការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនក្នុងជីវភាពប្រចាំថ្ងៃ ចាប់តាំងពីការខ្ចីប្រាក់ជារៀលរហូតដល់ទំនិញនៅតាមទីផ្សារ ការវិនិយោគសោធននិវត្តន៍ជាដើម ។ ចរាចរណ៍ប្រាក់រៀលកាន់តែច្រើននៅលើទីផ្សារ នឹងពង្រឹងសេដ្ឋកិច្ចឲ្យកាន់តែមានភាពរឹងមាំប្រកបដោយចីរភាពនៅពេលអនាគត ។

ជាជំហានដំបូង យើងចាំបាច់ត្រូវយល់ពីសារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល ។





# មោទនភាពជាតិ និងសាមគ្គីភាពជាតិ

ប្រទេសនីមួយៗតែងតែមានរូបិយវត្ថុជាតិរបស់ខ្លួន ដែលតំណាងឲ្យអត្តសញ្ញាណជាតិ ។ វត្ថុមានរូបិយវត្ថុជាតិគឺជាមោទនភាពសម្រាប់ប្រជាជនទាំងអស់នៅក្នុងប្រទេស ។ ដោយសារតែរូបិយវត្ថុត្រូវបានប្រើប្រាស់ទូទៅនៅក្នុងសង្គម ចរាចរណ៍ក្រដាសប្រាក់ក្នុងចំណោមប្រជាជនគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការលើកនិងបង្កើនចំណេះដឹងដល់សាធារណជនអំពីព្រឹត្តការណ៍ប្រវត្តិសាស្ត្រ និងវប្បធម៌ ក៏ដូចជាស្ថានភាពសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសផងដែរ ។ នៅកម្ពុជា ក្រដាសប្រាក់រៀលអាចលើកប្រជាជនពីរីបុរសដែលមានកិត្តិនាមជាប្រវត្តិសាស្ត្រ (ឧទាហរណ៍ដូចជាព្រះមហាក្សត្រ) ឬប្រាង្គប្រាសាទនានា (ប្រាសាទនានា ដែលត្រូវបានបង្ហាញនៅលើក្រដាសប្រាក់) ។

តាមរយៈការប្រើប្រាស់រូបិយវត្ថុជាតិ យើងអាចរក្សានិងចែករំលែកនូវចំណេះដឹងពីប្រវត្តិសាស្ត្រ វប្បធម៌ និងអត្តសញ្ញាណជាតិ រួមទាំងអ្នកជំនាន់ក្រោយផងដែរ ហើយនឹងអាចពង្រឹងនូវស្មារតីបង្រួបបង្រួមជាតិ ក្នុងនាមជាប្រជាជននៅក្នុងសង្គម និងជាតិតែមួយ ។



# រក្សាស្ថិរភាពថ្លៃ

តាមទ្រឹស្តី ស្ថិរភាពថ្លៃត្រូវបានរក្សាតាមរយៈការគ្រប់គ្រងការផ្គត់ផ្គង់បរិមាណរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច ។ ដូចទៅនឹងទំនិញដែរ ការផ្គត់ផ្គង់រូបិយវត្ថុលើសទៅក្នុងចរាចរណ៍នឹងធ្វើឲ្យតម្លៃរូបិយវត្ថុថយចុះ ហើយក៏នឹងធ្វើឲ្យសម្ពាធអតិផរណាកើនឡើងផងដែរ ។ ផ្ទុយទៅវិញ ប្រសិនបើការផ្គត់ផ្គង់ទាបជាងតម្រូវការ នឹងធ្វើឲ្យរូបិយវត្ថុឡើងថ្លៃខ្ពស់ជាងកម្រិតសមស្រប ដែលអាចធ្វើឲ្យមានបរិត្តផរណា ។ ដូច្នេះ ទាំងការផ្គត់ផ្គង់លើសនិងខ្វះ សុទ្ធតែមានផលប៉ះពាល់ដល់តម្លៃទំនិញនៅលើទីផ្សារ ។

អតិផរណាខ្ពស់នឹងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន នៅពេលដែលទំនិញកាន់តែឡើងថ្លៃ ខណៈដែលបរិត្តផរណាមានផលអវិជ្ជមានចំពោះវិនិយោគិន ដោយសារតែផលចំណេញពីការវិនិយោគមានការថយចុះ ។ ប្រសិនបើការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានធ្វើឡើងមិនសមស្រប អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចអាចនឹងកើតឡើង ។

ដើម្បីរក្សាស្ថិរភាពថ្លៃ ធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ដោយស្រូបយក ឬចាក់បញ្ចូលរូបិយវត្ថុទៅក្នុងទីផ្សារ ។ នៅកម្ពុជា ដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ ហើយរូបិយប័ណ្ណបរទេសចរាចរដោយសេរី (ប្រការនេះ លើសពីដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា) ធនាគារជាតិនៃកម្ពុជាមិនអាចកំណត់ពីចំនួនប្រាក់ដុល្លារអាមេរិកនិងរូបិយប័ណ្ណផ្សេងៗទៀតដែលកំពុងចរាចរនៅក្នុងសេដ្ឋកិច្ចបានទេ ។ ដូច្នេះប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ក៏ត្រូវបានកំហិតផងដែរ ។














# កាត់បន្ថយចំណាយប្រតិបត្តិការ

ការប្រើប្រាស់រូបិយប័ណ្ណលើសពីមួយនៅក្នុងសេដ្ឋកិច្ច បានបង្កើនចំណាយប្រតិបត្តិការ ទាំងពេលវេលា និងប្រាក់កាស ។ ទំនិញនិងសេវាអាចនឹងត្រូវបានគិតថ្លៃជារូបិយប័ណ្ណផ្សេងៗគ្នា អាស្រ័យលើ ៖ ក)- ប្រភពដើមនៃទំនិញនិងសេវាទាំងនោះ (ផលិតក្នុងស្រុកឬនាំចូល) ខ)- ទំហំប្រតិបត្តិការ (តូចឬធំ) គ)- និងប្រភេទទីផ្សារ (ប្រពៃណីឬទំនើប) ។ ដោយសារតែប្រាក់រៀលនិងដុល្លារអាមេរិកចរាចរទន្ទឹមគ្នា អ្នកទិញប្រឈមនឹងការខាតបង់អាស្រ័យលើប្រាក់ដែលគេកាន់ ។ អត្រាប្តូរប្រាក់ត្រូវបានកំណត់ដោយអ្នកលក់ ដោយមិនផ្អែកលើអត្រាទីផ្សារ និងមានទំនោរផ្តល់អត្ថប្រយោជន៍ដល់អ្នកលក់ ។ ឧទាហរណ៍ អ្នកទិញត្រូវប្តូរប្រាក់ មុននឹងទូទាត់ឲ្យអ្នកលក់ ដែលធ្វើឲ្យខាតទាំងពេលវេលា និងប្រាក់កាស ។ អ្នកលក់ក៏ខាតទាំងពេលវេលានិងប្រាក់កាសផងដែរ នៅពេលដែលពួកគេកំណត់ថ្លៃទំនិញជារូបិយប័ណ្ណផ្សេងៗគ្នា ។ អ្នកលក់ប្រឈមនឹងផលលំបាកចំពោះការធ្វើកិច្ចបញ្ជិកាគណនេយ្យ នៅពេលដែលរូបិយវត្ថុ/រូបិយប័ណ្ណដែលគេទទួលបានខុសពីរូបិយវត្ថុ/រូបិយប័ណ្ណដែលគេប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យ ។ ទាំងអ្នកលក់ និងអ្នកទិញ សុទ្ធតែប្រឈមនឹងហានិភ័យអត្រាប្តូរប្រាក់ នៅពេលដែលតម្លៃនៃរូបិយវត្ថុ/រូបិយប័ណ្ណប្រែប្រួល ។

ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយចំពោះការទូទាត់គ្រប់ប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ចជាតិ នឹងអាចជួយកាត់បន្ថយចំណាយជាច្រើនសម្រាប់អ្នកលក់និងអ្នកទិញ ។ លើសពីនេះ ការប្រើប្រាស់នេះនឹងអាចជួយបង្កើនប្រតិបត្តិការសេដ្ឋកិច្ចកាន់តែច្រើន ដោយសារភាពងាយស្រួល ឆាប់រហ័ស និងមានប្រសិទ្ធភាព នៅពេលដែលភាគីទាំងពីរមិនចាំបាច់ត្រូវខ្វល់ពីប្រភេទរូបិយវត្ថុ/រូបិយប័ណ្ណក្នុងការទូទាត់ ឬគម្លាតអត្រាប្តូរប្រាក់ទេ ។





# ជំរុញពាណិជ្ជកម្ម

សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកមួយភាគធំលើការនាំចេញ និងទេសចរណ៍ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ។ ក្នុងឆ្នាំ ២០១៤ ការនាំចេញ និងវិស័យទេសចរណ៍ មានប្រមាណ ៦១% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ។ ប្រសិនបើកម្ពុជាប្រើប្រាស់តែប្រាក់រៀល ធនាគារកណ្តាលអាចជំរុញការនាំចេញដោយធ្វើឲ្យភាពប្រកួតប្រជែងថ្លៃកើនឡើង តាមរយៈការបន្ថយតម្លៃរូបិយវត្ថុ ។ ការបន្ថយតម្លៃរូបិយវត្ថុនឹងធ្វើឲ្យការនាំចេញកើនឡើង ។

អំណាចក្នុងការបន្ថយតម្លៃរូបិយវត្ថុជាសមត្ថកិច្ចរបស់ធនាគារកណ្តាល ដោយមានការប្រឹក្សាជាមួយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធតាក់តែងគោលនយោបាយនានា ។ ឧទាហរណ៍ ដើម្បីផលិតខោ ១ ត្រូវចំណាយប្រាក់ ៤.០០០រៀល ។ ប្រសិនបើអត្រាប្តូរប្រាក់ស្ថិតនៅកម្រិត ៤.០០០រៀល ក្នុង ១ដុល្លារអាមេរិក ដៃគូពាណិជ្ជកម្មនឹងត្រូវការប្រាក់ ១ដុល្លារអាមេរិក ដើម្បីទិញខោនេះ ។ ប៉ុន្តែ ប្រសិនបើប្រាក់រៀលធ្លាក់ថ្លៃដល់ ៤.២០០រៀល ក្នុង ១ដុល្លារអាមេរិក អ្នកនាំចេញនឹងត្រូវការប្រាក់ត្រឹមតែ ០,៩៥ដុល្លារអាមេរិក ដើម្បីទិញខោនេះ ដែលធ្វើឲ្យខោនេះមានតម្លៃទាបជាងមុននៅលើទីផ្សារអន្តរជាតិ ។ នៅពេលតម្លៃទំនិញកាន់តែទាប អ្នកប្រើប្រាស់កាន់តែអាចទិញបានច្រើន ដែលនាំឲ្យតម្រូវការកើនឡើង ក៏ដូចជាបង្កើតការងារកាន់តែច្រើននៅកម្ពុជាផងដែរ ។ ដោយសារធាតុចូលក្នុងផលិតកម្ម ដូចជាវត្ថុធាតុដើម និងប្រាក់ឈ្នួល ត្រូវបានគិតជាប្រាក់ដុល្លារអាមេរិក ការធ្លាក់ថ្លៃនៃប្រាក់រៀលនឹងមិនមានឥទ្ធិពលលើថ្លៃទំនិញនាំចេញនោះទេ ដែលនឹងបណ្តាលឲ្យកម្ពុជាបាត់បង់ឱកាសក្នុងការជំរុញការនាំចេញនិងកំណើនសេដ្ឋកិច្ចថែមទៀតផង ។ ស្រដៀងគ្នានេះដែរ ការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុអាចទាក់ទាញភ្ញៀវទេសចរច្រើនជាងមុនមកកាន់កម្ពុជា និងធ្វើឲ្យពួកគេចំណាយកាន់តែច្រើន ដោយសារទំនិញកម្ពុជាមានតម្លៃទាបជាងមុនបើគិតជារូបិយប័ណ្ណ ។ ការបាត់បង់សមត្ថកិច្ចក្នុងការគ្រប់គ្រងតម្លៃប្រាក់រៀលបានបង្កជាការរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។









# ជំរុញការវិនិយោគ និងបង្កើតការងារ

ធនាគារកណ្តាលជាច្រើន ដូចជាធនាគារកណ្តាលអាមេរិក បានកែតម្រូវអត្រាការប្រាក់គោលរបស់ខ្លួន ដើម្បីជំរុញការវិនិយោគក្នុងស្រុកនិងបង្កើតការងារបន្ថែម ។ កម្រិតអត្រាការប្រាក់គោលដែលកំណត់ដោយធនាគារកណ្តាល មានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគ ហើយជាលទ្ធផលក៏នាំឲ្យមានការប្រែប្រួលដល់អត្រាការប្រាក់ដែលធនាគារកំណត់លើកម្ចីទៅកាន់វិនិយោគិននិងអង្គភាពគ្រួសារផងដែរ ។ នៅពេលដែលធនាគារកណ្តាលបន្ទាបអត្រាការប្រាក់គោល វាជាសញ្ញាដល់គ្រឹះស្ថានធនាគារក្នុងការកាត់បន្ថយអត្រាការប្រាក់កម្ចី ដែលនឹងធ្វើឲ្យកម្ចីមានតម្រូវការខ្ពស់ជាងមុនសម្រាប់វិនិយោគិននិងអង្គភាពគ្រួសារ ។ ធនាគារកណ្តាល ក៏អាចតម្លើងអត្រាការប្រាក់គោលប្រសិនបើមានសញ្ញាថា បរិមាណកម្ចីមានកំណើនខ្ពស់ហួសហេតុនៅក្នុងសេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យណាមួយ (ឧទាហរណ៍ វិស័យសំណង់ និងអចលនទ្រព្យ) ដើម្បីជៀសវាងការឡើងថ្លៃជ្រុល ។ ទ្រឹស្តីនេះអាចអនុវត្តបានតែក្នុងសេដ្ឋកិច្ចដែលប្រើប្រាស់រូបិយវត្ថុក្នុងស្រុកទាំងស្រុងឬមួយភាគធំប៉ុណ្ណោះ ។ នៅក្នុងករណីកម្ពុជា ប្រាក់បញ្ញើនិងឥណទានប្រមាណ ៩០% គឺជាប្រាក់ដុល្លារអាមេរិក ។ ផ្ទុយទៅវិញ ធនាគារជាតិនៃកម្ពុជា អាចផ្តល់តែកម្ចីជាប្រាក់រៀលប៉ុណ្ណោះដល់គ្រឹះស្ថានធនាគារ ។ មានន័យថា អត្រាការប្រាក់គោលដែលធនាគារជាតិនៃកម្ពុជាកំណត់ នឹងមិនមានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគរបស់គ្រឹះស្ថានធនាគារនោះទេ ។ ចំណុចនេះជាគុណវិបត្តិដ៏ធំមួយសម្រាប់ប្រជាជនកម្ពុជា និងវិនិយោគិនដែលកំពុងប្រឈមនឹងចំណាយថ្លៃដើមវិនិយោគខ្ពស់ ដោយសារធនាគារកណ្តាលមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនោះទេ ។





# លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម

ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែច្រើន អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើការគ្រប់គ្រងថវិកាបានកាន់តែប្រសើរ ដើម្បីសម្រេចបានតម្រូវការក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនិងសុខុមាលភាពសង្គម ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលធ្វើការប្រមូលចំណូលជាប្រាក់រៀល ប៉ុន្តែចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀតភាគច្រើនជាប្រាក់ដុល្លារអាមេរិក ។ នៅក្នុងរយៈកាលវែង ភាពមិនស៊ីគ្នានៃចំណូលជារូបិយវត្ថុនិងចំណាយជារូបិយប័ណ្ណនេះ នឹងជាឧបសគ្គសម្រាប់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងថវិកាឲ្យមានប្រសិទ្ធភាព ។

នៅកម្ពុជាការអនុវត្តគោលនយោបាយសារពើពន្ធត្រូវបានកម្រិតដោយបរិមាណប្រាក់ដុល្លារអាមេរិកដ៏ច្រើន នៅក្នុងសេដ្ឋកិច្ច ។ មូលហេតុនេះបានដាក់កំហិតដល់ការខ្ចីរបស់រាជរដ្ឋាភិបាលពីសាធារណជន ក្នុងការអភិវឌ្ឍគម្រោងអភិវឌ្ឍន៍អាទិភាពនានា ដូចជាការសាងសង់ ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ និងកម្មវិធីកាត់បន្ថយភាពក្រីក្រផ្សេងៗទៀត ។ ប្រសិនបើរាជរដ្ឋាភិបាលមានបំណងបង្កើនចំណាយសាធារណៈ រាជរដ្ឋាភិបាលមិនអាចខ្ចីប្រាក់ជារូបិយប័ណ្ណពីទីផ្សារក្នុងស្រុកនោះទេ ដោយសារតម្រូវការប្រាក់ដុល្លារនឹងកើនឡើង ដែលនឹងរឹតតែបង្កើនកម្រិតដុល្លារូបនីយកម្មនៅកម្ពុជា ។

ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យថវិកាជាតិមានភាពប្រសើរឡើង និងកាត់បន្ថយការដាក់កំហិតលើគោលនយោបាយសារពើពន្ធ ។ ប្រសិនបើនៅលើទីផ្សារមានប្រាក់រៀលកាន់តែច្រើន រាជរដ្ឋាភិបាលអាចពិចារណាចេញផ្សាយមូលបត្របំណុលជាប្រាក់រៀល ដើម្បីគ្រប់គ្រងថវិកា ក៏ដូចជាផ្តល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍នានា ។ ដូចនេះ លទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញប្បទានក្នុងស្រុក នឹងអាចជួយឲ្យកម្ពុជាកាត់បន្ថយការពឹងផ្អែកលើបំណុលបរទេស ។





# ជំរុញបរិយាប័ន្នហិរញ្ញវត្ថុ

យោងតាមការសិក្សារបស់ធនាគារពិភពលោក ការអភិវឌ្ឍសេដ្ឋកិច្ចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនត្រឹមតែមានសារៈសំខាន់ចំពោះឧស្សាហកម្មធនាគារប៉ុណ្ណោះទេ តែថែមទាំងជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ដែលអនុញ្ញាតឲ្យប្រជាជនកម្ពុជាអាចទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនិងមានតម្លៃសមរម្យ ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក ប្រជាជនពេញវ័យប្រមាណ ៤៦% អាចទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងប្រមាណ ២៣% មានគណនីនៅធនាគារ ។

ប្រជាជនកម្ពុជាប្រមាណ ៧០% កំពុងរស់នៅតាមតំបន់ជនបទ ហើយភាគច្រើនប្រកបរបរកសិកម្ម ។ ប្រាក់រៀលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដូចជាសម្រាប់ការផ្គត់ផ្គង់និងការចំណាយនានា ។ បច្ចុប្បន្ន គ្រឹះស្ថានហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅតាមជនបទ ទទួលបានមូលនិធិពីវិនិយោគិនបរទេសនិងពីអ្នកដាក់ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក ។ ដើម្បីបំពេញតម្រូវការប្រាក់រៀល គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះតែងតែប្តូរប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលអាចធ្វើឲ្យពួកគេប្រឈមនឹងហានិភ័យប្តូរប្រាក់ ។ ដើម្បីបង្ការហានិភ័យនេះ គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះបានកំណត់អត្រាការប្រាក់កម្ចីជាប្រាក់រៀលខ្ពស់ ដែលជាកត្តាធ្វើឲ្យកម្ចីជាប្រាក់រៀលមានអត្រាការប្រាក់ខ្ពស់ជាងកម្ចីជាប្រាក់ដុល្លារអាមេរិក ។

ចំពោះប្រជាជននៅតាមទីក្រុង ប្រតិបត្តិការភាគច្រើន ជាពិសេសធំៗជាទូទៅធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ដែលអនុញ្ញាតឲ្យពួកគេជៀសផុតពីហានិភ័យប្តូរប្រាក់បានមួយកម្រិតធំ ។ ផ្ទុយទៅវិញ ប្រជាជនដែលរស់នៅតាមជនបទភាគច្រើននិងប្រជាជនដែលមានចំណូលជារូបិយវត្ថុ ត្រូវប្រឈមនឹងអត្រាការប្រាក់កម្ចីខ្ពស់ ហើយប្រជាជនមួយចំនួនយល់ឃើញថា នេះជាឧបសគ្គចម្បងសម្រាប់ពួកគេក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុដូចជាការខ្ចីប្រាក់ពីធនាគារ ហើយមួយចំនួននៅតែបន្តខ្ចីពីអ្នកចងការប្រាក់ក្រៅផ្លូវការដែលទាញយកផលប្រយោជន៍ច្រើនហួសហេតុ ។ ការជំរុញការប្រើប្រាស់ប្រាក់រៀលតាមរយៈការសន្សំនិងសកម្មភាពសេដ្ឋកិច្ចផ្សេងៗ អាចជួយកាត់បន្ថយចំណាយនៃកម្ចីជាប្រាក់រៀល និងជំរុញបរិយាប័ន្នហិរញ្ញវត្ថុកម្ពុជា ។ ការណ៍នេះនឹងជំរុញកំណើនសេដ្ឋកិច្ចនៅតាមជនបទ ជាពិសេសវិស័យកសិកម្ម ដែលរួមចំណែកប្រមាណ ៣០% នៃផ.ស.ស ។









# គរពូនទុនបម្រុងអន្តរជាតិ

សម្រាប់ប្រទេសដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់ជាទូទៅ រូបិយប័ណ្ណដែលហូរចូលមកក្នុងប្រទេសត្រូវប្តូរទៅជារូបិយវត្ថុជាតិមុននឹងយកមកប្រើប្រាស់នៅក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ ធនាគារកណ្តាលមានតួនាទីស្រូបយករូបិយប័ណ្ណទាំងនេះតាមរយៈការប្តូរជារូបិយវត្ថុជាតិ ។ ប្រសិនបើមានតែប្រាក់រៀលដែលត្រូវបានប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច កម្ពុជាអាចបង្កើនទុនបម្រុងអន្តរជាតិបានយ៉ាងសន្ធឹកសន្ធាប់ តាមរយៈការគរពូនអតិរេកនៃលំហូររូបិយប័ណ្ណបរទេសមកក្នុងសេដ្ឋកិច្ចកម្ពុជាជារៀងរាល់ឆ្នាំ ។

ការគរពូនទុនបម្រុងអន្តរជាតិបង្កើនទ្រព្យសម្បត្តិជាតិ លើកកម្ពស់ជំនឿទុកចិត្តមកលើរូបិយវត្ថុ និងពង្រឹងមូលដ្ឋានរឹងមាំសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ទុនបម្រុងអន្តរជាតិដែលមានបរិមាណខ្ពស់សមស្រប ក៏នឹងអនុញ្ញាតឲ្យធនាគារកណ្តាលមានលទ្ធភាពខ្ពស់ក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីកាត់បន្ថយការប្រែប្រួលខ្លាំងនៃតម្លៃរូបិយវត្ថុជាតិក្នុងគោលបំណងសម្រេចបាននូវសមិទ្ធផលដែលគាំទ្រកំណើនសេដ្ឋកិច្ច ។ លើសពីនេះ កំណើនទុនបម្រុងអន្តរជាតិនឹងបង្កើនការវិនិយោគ ស្របតាមគោលការណ៍លំដាប់អាទិភាព ១- សុវត្ថិភាព ៖ វិនិយោគលើឧបករណ៍ហិរញ្ញវត្ថុដែលមានសុវត្ថិភាពក្នុងគោលបំណងចម្បងដើម្បីរក្សាដើមទុន ២- កម្រិតសន្ទនីយភាពខ្ពស់ ៖ រក្សាជាឧបករណ៍ដែលមានសន្ទនីយភាពខ្ពស់សម្រាប់យកទៅប្រើប្រាស់បានភ្លាមៗទៅតាមតម្រូវការរបស់ប្រព័ន្ធធនាគារ ៣- បង្កើនចំណូល ៖ វិនិយោគទៅលើឧបករណ៍ហិរញ្ញវត្ថុនានាដើម្បីទទួលបានប្រាក់ចំណេញ សំដៅគរពូនទុនបម្រុងអន្តរជាតិបន្ថែម ។ ប្រាក់ចំណេញនេះនឹងត្រូវបែងចែករវាងធនាគារកណ្តាល (សម្រាប់ចំណាយប្រតិបត្តិការ) និងរាជរដ្ឋាភិបាល ដែលអាចត្រូវបានយកទៅប្រើប្រាស់ក្នុងការវិនិយោគដើម្បីការអភិវឌ្ឍនៅក្នុងប្រទេសវិញ ។ ដូច្នេះ ថ្វីត្បិតតែមានបរិមាណសមស្របចំពោះទំហំសេដ្ឋកិច្ច ទុនបម្រុងអន្តរជាតិនៅកម្ពុជា អាចនឹងត្រូវបានគរពូនបន្ថែមយ៉ាងច្រើនថែមទៀត នៅពេលដែលប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយនៅក្នុងប្រទេស ។





# ទទួលបានចំណូលពីការបោះពុម្ពក្រដាសប្រាក់

ចំណូលពីការបោះពុម្ពក្រដាសប្រាក់គឺជាភាពខុសគ្នារវាងតម្លៃចារឹករបស់ក្រដាសប្រាក់និងចំណាយផលិតកម្ម ។ ឧទាហរណ៍ ក្រដាសប្រាក់ប្រភេទ ១០.០០០ រៀល ត្រូវការថ្លៃចំណាយបោះពុម្ពចំនួន ៣០០ រៀល ។ នៅពេលដែលក្រដាសប្រាក់ប្រភេទ ១០.០០០ រៀលនេះត្រូវបានបោះផ្សាយនិងដាក់ឱ្យចរាចរដល់សាធារណជន ក្រដាសប្រាក់នេះអាចទិញទំនិញក្នុងតម្លៃ ១០.០០០ រៀល។ ដូច្នេះ ចំណូលពីការបោះពុម្ពស្មើនឹង ៩.៧០០ រៀល ។ កំណើនតម្រូវការប្រាក់រៀលនឹងធ្វើឱ្យធនាគារជាតិនៃកម្ពុជាអាចបោះផ្សាយក្រដាសប្រាក់រៀលកាន់តែច្រើន ។ ជាលទ្ធផល នៅពេលដែលក្រដាសប្រាក់រៀលត្រូវបានបោះពុម្ពកាន់តែច្រើន នោះកម្ពុជានឹងអាចទទួលបានចំណូលពីការបោះពុម្ពកាន់តែច្រើនដែរ ។

សេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់បានដាក់កំហិតលើលទ្ធភាពរបស់ប្រទេសក្នុងការទទួលបានចំណូលពីការបោះពុម្ពនេះ ដោយសារសាធារណជនកាន់រូបិយប័ណ្ណជាចម្បង ជំនួសឱ្យរូបិយវត្ថុជាតិ ។ ដូច្នេះ ការកាន់កាប់រូបិយប័ណ្ណមានន័យស្មើនឹងការខាតបង់ចំណូលពីការបោះពុម្ព ។ លើសពីនេះ ការកាន់កាប់នេះក៏ធ្វើឱ្យកម្ពុជាបាត់ឱកាសទទួលបាននូវចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើនិងការវិនិយោគរូបិយប័ណ្ណ (ដែលត្រូវស្រូបយកដោយធនាគារកណ្តាលក្នុងករណីគ្មានដុល្លារូបនីយកម្ម) នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ។

តាមរយៈការបោះពុម្ពក្រដាសប្រាក់រៀលកាន់តែច្រើន រាជរដ្ឋាភិបាលនឹងទទួលបានមូលនិធិក្នុងនាមជាអ្នកខ្ចីពីសេដ្ឋកិច្ចដោយមិនមានការប្រាក់ ដើម្បីយកទៅធ្វើការវិនិយោគទៅក្នុងសេដ្ឋកិច្ចឬបង្កើនចំណាយសំដៅអភិវឌ្ឍវិស័យសេដ្ឋកិច្ចអាទិភាពនានា ។



NBC staff member inspecting new U.S. dollar bills, Phnom Penh, Cambodia.

# បញ្ហាការក្លែងក្រដាសប្រាក់

ដោយសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ក្រដាសប្រាក់ជាមូលដ្ឋាន ជាពិសេសការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយ កម្ពុជាអាចជាគោលដៅនៃការហូរចូលនៃក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ ដោយសារតែសាធារណជនមិនស្គាល់ច្បាស់ពីរូបិយប័ណ្ណបរទេស និងមិនអាចបែងចែករវាងក្រដាសប្រាក់ពិតនិងក្លែងក្លាយ ដូចជាតាមរយៈរូបភាព និងលក្ខណៈនៃក្រដាសប្រាក់រូបិយប័ណ្ណបរទេស ។ ក្នុងបរិការណ៍នេះ ការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ប្រាក់រៀលកាន់តែទូលំទូលាយ មានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការចរាចររូបិយប័ណ្ណក្លែងក្លាយនៅកម្ពុជា ហើយក៏រួមចំណែកកាត់បន្ថយកម្រិតដុល្លារូបនីយកម្មបន្តិចម្តងៗផងដែរ ។

ការប្រើប្រាស់រូបិយវត្ថុជាតិដែលប្រជាជនស្គាល់ច្បាស់នឹងជួយកាត់បន្ថយនូវការក្លែងក្រដាសប្រាក់ និងជួយបង្ការការក្លែងក្រដាសប្រាក់លើរូបិយប័ណ្ណបរទេសដោយសារតែរូបិយប័ណ្ណទាំងនេះ នឹងហូរចូលទៅក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារ ។



**ធនាគារជាតិនៃកម្ពុជា**
ឡូតិ៍លេខ ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
អ៊ីម៉ែល: info@nbc.org.kh
គេហទំព័រ: http://www.nbc.org.kh